**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** : ........២៧០........ក.ប/ស.ជ.ណ

## សេចក្តីជូនដំណឹង
## ស្តីពីការចុះឈ្មោះបោះឆ្នោត

យោងសេចក្តីជូនដំណឹងលេខ៣៨៦/១៦ គ.ជ.ប ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីឯកសារសម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់រោងចក្រ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវស្មារតីនៃសេចក្តីជូនដំណឹងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនេះ។ ក្នុងករណីមានចម្ងល់ សូមទំនាក់ទំនងជាមួយការិយាល័យចុះឈ្មោះបោះឆ្នោតដែលនៅជិតរោងចក្រ សហគ្រាស គ្រឹះស្ថាន ឬទីសំណាក់របស់បងប្អូនកម្មករនិយោជិត។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជឿជាក់ថា បងប្អូនកម្មករនិយោជិតទាំងអស់ នឹងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ :(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩